# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារ សហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងអនុក្រឹត្យលេខ ០២.អនក្រ.បក ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

### មាត្រា ១ .-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ- ថៃ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- | ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធានទី១ |
| ៣- | ឯកឧត្តម ប៉ាន សូរស័ក្តិ | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធានទី២ |
| ៤- | ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥- | ឯកឧត្តម ត្រាំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦- | ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧- | ឯកឧត្តម ចំន្ទ គុនអ៊ីវ | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- | ឯកឧត្តម នុត ណារ៉ាង | រដ្ឋលេខាធិការ ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- | ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០- | ឯកឧត្តម អេង ហ៊ុត | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១១- | ឯកឧត្តម ខុន សំនួន | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១២- | ឯកឧត្តម ស៊ឹម សុន | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣- | ឯកឧត្តម ស្រ៊ុន តារា | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤- | ឯកឧត្តម ជុំ សម្បុន | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១៥- | ឯកឧត្តម ហ៊ុំ តាំងអេង | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៦- | ឯកឧត្តម ហាក់ ស៊ីងលី | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៧- | ឯកឧត្តម ប៉ុល ម៉េងហួរ | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៨- | ឯកឧត្តម គួច សារ៉ូ | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៩- | ឯកឧត្តម ហែម សាងម | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង | សមាជិក |
| ២០- | ឯកឧត្តម លាភ វណ្ណៈដេន | អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១- | ឯកឧត្តម សេង សក្ដា | អគ្គនាយកការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក តេង សាវុង | អនុប្រធានអចិន្ត្រៃយ៍នៃ អ.ជ.ប.គ.ញ | សមាជិក |
| ២៣- | ឯកឧត្តមឧត្តមសេនីយ៍ទោ ជា ម៉ន | មេបញ្ជាការយោធភូមិភាគទី ៤ | សមាជិក |
| ២៤- | ឯកឧត្តម គីមរ៉េត សំរេច | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ២៥- | លោក ទិន សុនហាក់ | ប្រធាននាយកដ្ឋានស្រាវជ្រាវអប់រំ ផ្សព្វផ្សាយធម្មទេសនា | សមាជិក |
| ២៦- | តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | | សមាជិក |
| ២៧- | ឯកឧត្តមអភិបាលខេត្តសៀមរាប | | សមាជិក |
| ២៨- | ឯកឧត្តមអភិបាលខេត្តឧត្តរមានជ័យ | | សមាជិក |
| ២៩- | ឯកឧត្តមអភិបាលខេត្តព្រះវិហារ | | សមាជិក |
| ៣០- | ឯកឧត្តមអភិបាលខេត្តស្ទឹងត្រែង | | សមាជិក |

**មាត្រា ២ ..**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានភារកិច្ច ដូចតទៅ :

- សិក្សា-រៀបចំគម្រោង និងកម្មវិធីដែលត្រូវអភិវឌ្ឍន៍ដោយឡែក និងអភិវឌ្ឍន៍រួមគ្នា ជាពិសេសលើវិស័យទេសចរណ៍ នៅក្នុងតំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ
- ធ្វើជាដៃគូចរចារួមថ្នាក់រដ្ឋមន្ត្រី ជាមួយភាគីឡាវ និងភាគីថៃ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ និងរួមគ្នាចរចាជាមួយភាគីផ្តល់ជំនួយទាំងអស់ ដើម្បីរកថវិកាមកអនុវត្តគម្រោងដែលបានសិក្សារួច និងដែលនឹងត្រូវសិក្សាសម្រាប់អភិវឌ្ឍន៍នៅពេលខាងមុខ
- គិតគូរអំពីតុល្យភាព នៃការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ត្រីកោណមរកត និងអត្ថប្រយោជន៍ទាំងឡាយដែលប្រជាជនកម្ពុជានឹងត្រូវទទួលបាន
- សិក្សា និងលើកយោបល់ជូនរាជរដ្ឋាភិបាល អំពីផលប៉ះពាល់នៃការអនុវត្តន៍គម្រោងនានា មកលើបរិស្ថាន វប្បធម៌ ប្រពៃណី-សាសនា និងទំនៀមទំលាប់នៅក្នុងតំបន់ត្រីកោណមរកត
- រៀបចំកម្មវិធី និងគម្រោងវិនិយោគអាទិភាព លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងកសាងធនធានមនុស្ស
- រៀបចំផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច អប់រំ បណ្តុះបណ្តាល សុខាភិបាល ទេសចរណ៍ ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គមនិងបង្ក្រាបបទល្មើសឆ្លងដែននៅក្នុង និងឆ្លងកាត់តំបន់ត្រីកោណមរកត
- ទំនាក់ទំនង និងកៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេសសម្រាប់ការសិក្សាស្រាវជ្រាវ និងអនុវត្តកម្មវិធី និងគម្រោងអាទិភាពទាំងឡាយ
- ពង្រឹងការឯកភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ផ្សេងៗទៀត គួបផ្សំជាមួយកិច្ចសហប្រតិបត្តិការនៅតំបន់ត្រីកោណមរកត
- គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា ឡាវ-ថៃ ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច
- បំពេញការងារដទៃទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល

**មាត្រា ៣ ..**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ ថៃ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្មលើរាល់លិខិតស្នាមផ្លូវការ និងមានថវិកាដោយឡែក សម្រាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម។

សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងធ្វើការងារ ប្រសិនជាយល់ឃើញថា មានការចាំបាច់។

**មាត្រា ៤.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ អាចបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ។

**មាត្រា ៥.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា ឡាវ-ថៃ មានលេខាធិការដ្ឋានដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌពីក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

**មាត្រា ៦.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានភារកិច្ច ដូចតទៅ :

- ជាសេនាធិការរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ
- សម្របសម្រួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានជាអាទិ៍ រៀបចំផែនការការងារ និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ និងសម្របសម្រួលការងារជាមួយអនុគណៈកម្មការជំនាញ
- សម្របសម្រួលការងារជាមួយប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការនានា។
- បំពេញការងារដទៃ តាមការណែនាំរបស់របស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ